

# ស្បែកជើងរបស់ប៉ាម៉ូម៉ូ

Saptorini

Weny Amalia

Let's Read

The Asia Foundation




អា! ប៉ាប៉ាមកផ្ទះវិញហើយ។
ខ្ញុំឮសូរស្នូរស្បែកជើងរបស់ប៉ាប៉ាលាន់ ឌឹប ឌឹប ឌឹប!



ឌឹប ឌឹប ឌឹប!

ស្បែកជើងប៉ាប៉ា ឮសូរដូចស្នូរបាល់កំពុងលោតចុះលោតឡើងអ៊ីចឹង។ ប៉ុន្តែខ្ញុំស្គាល់ច្បាស់ថា នោះជាស្នូរស្បែកជើងរបស់ប៉ាប៉ា។



ឪពុករបស់ម៉ូម៉ូបានឱ្យម៉ូម៉ូខ្ចីស្បែកជើងពាក់។ ម៉ូម៉ូចង់ពាក់ស្បែកជើងនោះឱ្យឮសូរ ឌឹប ឌឹប ឌឹប ដែរ។



ស្បែកជើងរបស់ប៉ាប៉ាធំណាស់។ ស្បែកជើងនេះធំសឹងតែប៉ុនខ្លួនខ្ញុំទៅហើយ។



ស្បែកជើងរបស់ប៉ាប៉ាខ្ពស់ណាស់។



ឥឡូវនេះ ខ្ញុំចង់ពាក់ស្បែកជើងនេះ ហើយបោសសំអាតមុខផ្ទះ
ដូចប៉ាប៉ាធ្លាប់ធ្វើដែរ។
អូ! ស្បែកជើងនេះធ្ងន់ណាស់។
ចុះហេតុអ្វីស្បែកជើងនេះមិនឮសូរ ឌឹប ឌឹប ឌឹប អ៊ីចឹង?



ហ៊ឺ! ប្រហែលជាខ្ញុំត្រូវលើកជើងឱ្យខ្ពស់ហើយ។
អែយ៉ា! ស្បែកជើងនេះធ្ងន់ណាស់។



ម៉ូម៉ូរអិលដួលព្រួស ធ្វើឱ្យសំរាមរាយពាសពេញដី។
តើម៉ូម៉ូត្រូវធ្វើដូចម្តេចដើម្បីសំអាតវាឱ្យស្អាតវិញ?



ខ្ញុំដោះស្បែកជើងនេះចេញសិន។
អ៊ែយ៉ូយ! ស្រមោចខាំជើងខ្ញុំហើយ។



អូ! ស្រមោចទាំងនេះផ្តុំគ្នានៅពេលវាសែងចំណីមកទេតើ។
មើលទៅពួកវាដូចជារទេះភ្លើងដឹកចំណីអ៊ីចឹង។



ឆុកឆាក់ ឆុកឆាក់!

កូនឡានរបស់ខ្ញុំក៏អាចដឹកអីវ៉ាន់ដូចរទេះភ្លើងបានដែរ។

ឆុកឆាក់ ឆុកឆាក់!



ម៉ូម៉ូដាក់សំបកដបនៅក្នុងកូនឡានពណ៌លឿង។
ម៉ូម៉ូដាក់សំរាមផ្សេងទៀតនៅក្នុងឡានពណ៌ក្រហម។



ម៉ូម៉ូប្រមូលស្លឹកឈើដាក់នៅក្នុងឡានពណ៌បៃតង តែឡាននោះតូចពេក។



អូ! ខ្ញុំដាក់ស្លឹកឈើនៅក្នុងស្បែកជើងរបស់ប៉ាប៉ាវិញ។
ស្បែកជើងរបស់ប៉ាប៉ាក៏អាចដឹកអីវ៉ាន់បានដែរ។



ឆុកឆាក់ ឆុកឆាក់! ឌឹប ឌឹប ឌឹប!

ជយោ! ខ្ញុំមានរទេះភ្លើងយ៉ាងវែងមួយហើយ។

ឆុកឆាក់ ឆុកឆាក់! ឌឹប ឌឹប ឌឹប!



ឪពុករបស់ម៉ូម៉ូរីករាយណាស់ដែលម៉ូម៉ូចេះបោសសំអាតដូចគាត់ដែរ។

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org


**Original Story**

*Sepatu Bot Malik (Malik's Boots)*, Author: Saptorini. Illustrator: Weny Amalia. Published by The Asia Foundation - Let's Read, © The Asia Foundation - Let's Read. Released under CC BY-NC 4.0.



This work is a modified version of the original story. © The Asia Foundation, 2020. Some rights reserved. Released under CC BY-NC 4.0.

For full terms of use and attribution,
http://creativecommons.org/licenses/by-nc/4.0/